**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យ សិរីសួស្តី បវរមហាប្រសើរជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី។

ឆ្លៀតក្នុងឱកាសដ៏សោមនស្សរីករាយនេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមនោសញ្ចេតនាគោរពនិងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំពោះវីរភាពដ៏ឧត្តុង្គឧត្តមនិងថ្លៃថ្លាបំផុតក្នុងសកម្មភាពស្នេហាជាតិមាតុភូមិកម្ពុជាប្រកបដោយកក្តីភាពបំផុតដែល**សម្តេច**បានយកអស់កម្លាំងកាយចិត្ត ពុះពារ លះបង់ ប្រឹងប្រែងក្នុងការជួយដោះស្រាយទុក្ខលំបាករបស់ប្រជាជនគ្រប់កាលៈទេសៈ តាមរយៈចលនាកាកបាទក្រហមកម្ពុជា ដែលរាល់សកម្មភាពទាំងនេះបានបង្ហាញឱ្យឃើញយ៉ាងប្រត្យក្សនូវគំរូវីរភាពជាស្ត្រីឆ្នើមមួយរូបរបស់ប្រទេសជាតិ ជាភរិយា និងជាមាតាដ៏ប្រសើរឧត្តម។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ-សុខា**